# គោលជំនឿក្រុមប្រឹក្សាណាយស៊ីន

## Nicene Creed

យើងជឿលើព្រះជាម្ចាស់តែមួយ

គឺព្រះវរបិតា ជាព្រះដ៏មានអំណាចគ្រប់ព្រះចេស្ដា

ព្រះអង្គបានបង្កើតឋានសួគ៌និងភពផែនដីព្រមទាំង

គ្រប់របស់ទាំងអស់ដែលមើលឃើញនិងមើលមិនឃើញ។

យើងជឿលើព្រះអម្ចាស់តែមួយ

គឺព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រាតែមួយគត់នៃព្រះជាម្ចាស់

ដែលមានព្រះជន្មគង់នៅ រួមជាមួយព្រះវរបិតាតាំងពីអស់កល្បជានិច្ច

ជាព្រះជាម្ចាស់មកពីព្រះជាម្ចាស់ ជាពន្លឺមកពីពន្លឺ

ជាព្រះជាម្ចាស់ដ៏ពិត មកពីព្រះជាម្ចាស់ដ៏ពិត

បានមានឡើងតែមិនមានដោយការបង្កើតទេ

មានរូបអង្គតែមួយ នៅជាមួយនឹងព្រះវរបិតា។

តាមរយៈព្រះអង្គនោះអ្វីៗទាំងអស់ត្រូវបានបង្កើតមក។

សម្រាប់យើង និង សម្រាប់សេចក្ដីសង្គ្រោះ

នោះទ្រង់បានយាងចុះមកពីឋានសួគ៌។

ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ

នោះព្រះអង្គបានយកនិស្ស័យជាមនុស្សតាមរយៈនាងក្រមុំព្រហ្មចារីម៉ារា

ហើយបានកើតមកជាមនុស្ស។

ដោយគិតដល់ប្រយោជន៍យើងនោះព្រះអង្គត្រូវបានគេឆ្កាង

នៅក្រោមកណ្តាប់ដៃរបស់លោកប៉ុនទាសពីឡាត់។

ទ្រង់បានរងទុក្ខវេទនាដោយសុគតហើយព្រះបរមសពបានទទួលការបញ្ចុះ

នៅថ្ងៃទីបីព្រះអង្គបានមានព្រះជន្មរស់ឡើងវិញស្របតាមបទគម្ពីរ

ព្រះអង្គបានយាងទៅកាន់ឋានសួគ៌និងគង់នៅខាងស្តាំព្រះវរបិតា។

ព្រះអង្គនឹងយាងត្រឡប់មកវិញក្នុងសិរីរុងរឿងដើម្បីជំនុំជំរះ

មនុស្សទាំងអស់ទោះទាំងមនុស្សរស់និងមនុស្សស្លាប់ ហើយ

ព្រះរាជ្យរបស់ព្រះអង្គស្ថិតស្ថេរអស់កល្បជានិច្ចតរៀងទៅ។

យើងជឿលើព្រះវិញ្ញាណបរិសុទ្ធ ដែលជាព្រះអម្ចាស់ ដែលជា

ព្រះអង្គប្រទានជីវិត ដែលបានយាងមកពីព្រះវរបិតានិងព្រះរាជបុត្រា។

ព្រះអង្គជាព្រះដែលយើងត្រូវថ្វាយបង្គំ និងសរសើរតម្កើងរួមជាមួយព្រះវរបិតានិងព្រះរាជបុត្រា។

ព្រះអង្គបានសម្តែងព្រះបន្ទូលតាមរយៈពួកហោរា។

យើងជឿលើពួកជំនុំពួកសាវក និង ពួកជំនុំសកលដ៏បរិសុទ្ធ។

យើងទទួលស្គាល់ពិធីបុណ្យជ្រមុជទឹកតែមួយសម្រាប់ការអត់ទោសបាប។

យើងទន្ទឹងរង់ចាំការរស់ឡើងវិញនៃអស់អ្នកដែលបានស្លាប់

និងជីវិតនៃពិភពលោកថ្មីដែលនឹងត្រូវមកដល់។ អាម៉ែន។